**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

**អគ្គលេខាធិការដ្ឋាន**

លេខ : ៥៤៤/១០ អ.រ.ស.ជ.ណ

# សេចក្តីជូនដំណឹង

**យោង** : -មាត្រា ១៣៧ ថ្មី និងមាត្រា ១៣៨ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-មាត្រា ៣ និងមាត្រា ៤ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

អគ្គលេខាធិការដ្ឋានរដ្ឋសភា មានកិត្តិយសសូមជម្រាបជូន សាធារណជនមេត្តាជ្រាបថា រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នឹងធ្វើការជ្រើសតាំងឥស្សរជន (០១) រូបក្នុងតំណែងជាសមាជិកក្រុមប្រឹក្សា ធម្មនុញ្ញសម្រាប់អាណត្តិថ្មី ។

ឥស្សរជនដែលមានបំណងចូលរួមក្នុងការជ្រើសតាំងនេះ ត្រូវបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម ៖

| | |
|---|---|
| ១- ត្រូវមានពាក្យសុំឈរឈ្មោះជាបេក្ខជនសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ | ០១ ច្បាប់ |
| ២- មានជីវប្រវត្តិសង្ខេបរបស់បេក្ខជន | ០១ ច្បាប់ |
| ៣- មានលិខិតបញ្ជាក់ថា ពិតជាមានអាយុយ៉ាងតិច ៤៥ ឆ្នាំ | ០១ ច្បាប់ |
| ៤- មានលិខិតបញ្ជាក់ថា មានបទពិសោធន៍យ៉ាងតិច ១៥ ឆ្នាំ | ០១ ច្បាប់ |
| ៥- មានសញ្ញាប័ត្រ ឬលិខិតបញ្ជាក់ថាបានប្រឡងជាប់ឧត្តមសិក្សាផ្នែកខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត ឬខាងសេដ្ឋកិច្ច | |
| ៦- មានលិខិតថ្កោលទោស (អាចផ្តល់ជូននៅពេលក្រោយ) | ០១ ច្បាប់ |
| ៧- មានរូបថតទំហំ ៤ x ៦ (ថតចំពីមុខ) គ្មានពាក់វ៉ែនតា ចំនួន | ០៣ សន្លឹក |
| ៨- មានហត្ថលេខាគាំទ្របេក្ខជនពីសមាជិករដ្ឋសភាចំនួន ១៣ រូប | ០១ ច្បាប់ |

អគ្គលេខាធិការដ្ឋានរដ្ឋសភា នឹងទទួលពាក្យសុំឈរឈ្មោះជាបេក្ខជន នៅរៀងរាល់ម៉ោងធ្វើការ ពេលព្រឹកចាប់ពីម៉ោង ៧:០០ ដល់ម៉ោង ១១:៣០ នាទី ពេលល្ងាចចាប់ពីម៉ោង ១៤:០០ ដល់ម៉ោង ១៧:៣០ នាទី នៅនាយកដ្ឋានគ្រប់គ្រងបុគ្គលិក នៃ អគ្គនាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ ។

កាលបរិច្ឆេទទទួលពាក្យសុំត្រូវផុតកំណត់នៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១០ វេលាម៉ោង ១៧:៣០ នាទី ។

ព័ត៌មានផ្សេងៗ សូមទាក់ទងនាយកដ្ឋានគ្រប់គ្រងបុគ្គលិក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋាន រដ្ឋសភា ។

ភ្នំពេញ, ថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០១០

**អគ្គលេខាធិការរដ្ឋសភា**

**ឡេង ប៉េងឡុង**

<u>ទូរស័ព្ទទំនាក់ទំនង</u> :

- ទូរស័ព្ទការិយាល័យលេខ : ០២៣ ២២២ ៦០៥
- ទូរស័ព្ទដៃលេខ : ០១៦ ៨៨៩ ៩០៥
- ទូរស័ព្ទដៃលេខ : ០១៦ ៨៩១ ៩៩១
- ទូរស័ព្ទដៃលេខ : ០១២ ៨៩៤ ៩២០